# ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ

សាលាដំបូង

ខេត្តបន្ទាយមានជ័យ

បណ្តឹងរដ្ឋប្បវេណីលេខ : ២១៥

ចុះថ្ងៃទី១៥ ខែតុលា ឆ្នាំ២០១០

កាលបរិច្ឆេទបញ្ចប់ការទាញហេតុផល

ដោយផ្ទាល់មាត់

ចុះថ្ងៃទី០៨ ខែកុម្ភៈ ឆ្នាំ២០១១

សាលក្រមលេខ:០៤ (ក)

កាលបរិច្ឆេទប្រកាសសាលក្រម

ចុះថ្ងៃទី២២ ខែកុម្ភៈ ឆ្នាំ២០១១

## នាមនាមប្រជារាស្ត្រខ្មែរ

## សាលាដំបូងខេត្តបន្ទាយមានជ័យ

## ដែលបានសម្រេចចេញសាលក្រមដែលមាន

- ដើមចោទ : ឈ្មោះ [redacted] ថាច ភេទស្រី អាយុ ៥៩ ឆ្នាំ ជនជាតិខ្មែរ សញ្ជាតិខ្មែរ មានទីលំនៅបច្ចុប្បន្នភូមិអូរអំបិល សង្កាត់អូរអំបិល ក្រុងសិរីសោភ័ណ ខេត្តបន្ទាយមានជ័យ ។
- ចុងចម្លើយ : ឈ្មោះ [redacted] សុឃឹម ភេទស្រី អាយុ៣២ ឆ្នាំ ជនជាតិខ្មែរ សញ្ជាតិខ្មែរ មានទីលំនៅបច្ចុប្បន្ន ភូមិអូរអំបិល សង្កាត់អូរអំបិល ក្រុងសិរីសោភ័ណ ខេត្តបន្ទាយមានជ័យ ។

### អង្គហេតុ និងចំណុចវិវាទ

**ក.សាលក្រមដែលទាមទារដោយភាគី :**

*- ភាគីដើមចោទ សុំអោយតុលាការចេញ សាលក្រមដូចតទៅ :-*

៥- សុំបញ្ជាក់ទទួលស្គាល់ សិទ្ធិកាន់កាប់ និងប្រគល់អចលនវត្ថុ នៃផ្ទះល្វែងទំហំ៦៨ ម៉ែត្រការ៉េដែលមាន នៅក្នុងប័ណ្ណលក់ ផ្ទះល្វែងទីផ្សារដើមគរលេខ: ០៣ គ ៖ ជ .លអប ចុះថ្ងៃទី ០១ ខែមីនា ឆ្នាំ ១៩៩៣ ចេញដោយប្រធានគណៈកម្មការរៀបចំផ្សារ ដែលស្ថិតនៅភូមិអូរអំបិល សង្កាត់អូរអំបិល ក្រុងសិរីសោភ័ណ ខេត្តបន្ទាយមានជ័យ ឱ្យទៅឈ្មោះ [redacted] ថាច ជាម្ចាស់កម្មសិទ្ធិ ។

៦- សុំឱ្យចុងចម្លើយឈ្មោះ [redacted] សុឃឹម ចុះចេញពីផ្ទះល្វែងទំហំ ៦៨ ម៉ែត្រការ៉េដែលមាន នៅក្នុងប័ណ្ណលក់ផ្ទះល្វែងទីផ្សារដើមគរលេខ ០៣ គរជ/ល អ បចុះថ្ងៃទី០១ ខែមីនា ឆ្នាំ១៩៩៣ ចេញដោយប្រធាន គណៈកម្មការរៀបចំផ្សារ ដែលស្ថិតនៅភូមិអូរអំបិល សង្កាត់អូរអំបិល ក្រុងសិរីសោភ័ណ ខេត្តបន្ទាយមានជ័យ ។

៧- ឱ្យចុងចម្លើយទទួលបន្ទុក ប្រាក់ពន្ធបណ្តឹង និងប្រាក់ប្រដាប់ក្តី ។

៨- ទាមទារឱ្យ ចុងចម្លើយសងជំងឺចិត្តការខាតបង់ពេលវេលា ចំនួន ៥ 000 000 ៛ ( ប្រាំលានរៀល ) ។

**ខ . ការពន្យល់ អង្គហេតុ មានដូចតទៅ :**

កាលពីឆ្នាំ២០០១ ឈ្មោះ [redacted] ថាច បានទិញផ្ទះ និងដីសំរាប់សង់ផ្ទះល្វែង ពីឈ្មោះ [redacted] អេងណៃ និង ប្តីឈ្មោះ [redacted] ហួរ ទំហំ៦៨ ម៉ែត្រការ៉េ ដែលមាននៅក្នុងប័ណ្ណលក់ ផ្ទះល្វែងទីផ្សារដើមគរលេខ :០៣ គរជ .លអប ចុះថ្ងៃទី០១ ខែមីនា ឆ្នាំ១៩៩៣ ចេញដោយប្រធានគណៈកម្មការរៀបចំផ្សារ ដែលស្ថិតនៅភូមិអូរអំបិល សង្កាត់អូរអំបិល ក្រុងសិរីសោភ័ណខេត្តបន្ទាយមានជ័យ ក្នុងតម្លៃ ២៧០ 000 B (ពីររយចិតសិបពាន់បាត ) ។ លុះដល់ឆ្នាំ២០០២ ឈ្មោះ [redacted] ថាច/



Scanned with CamScanner

(57/3)

បានធ្វើការជួសជុល និងពង្រីកបន្ថែមលើចំណែកដី ដែលនៅសល់ចំនួនមួយល្វែងទៀត បានជាពីរល្វែង ។ ក្នុងឆ្នាំ ២០០៥ ឈ្មោះ [redacted] គឹមហាង ត្រូវជាកូន របស់ឈ្មោះ [redacted] ថាច បានទទួលមរណៈភាពដោយគ្រោះថ្នាក់ចរាចរ ហើយក្រោយមកស្រាប់តែឈ្មោះ [redacted] សុឃីម ត្រូវជាកូនប្រសារបានបង្ខំឱ្យ ធ្វើបណ្តាំមរតកទៅឱ្យចៅ តែឈ្មោះ [redacted] ថាច ពុំយល់ព្រម ហើយឈ្មោះ [redacted] សុឃីម បានចាក់សោរមិនឱ្យឈ្មោះ [redacted] ថាច ចូលទៅរស់នៅ ទើបទំនាស់កើតឡើង ។

គ - អំពីចំណុចវិវាទ :

១- ដើមចោទឈ្មោះ [redacted] ថាច បានអះអាងថា : ផ្ទះល្វែងទំហំ៦៨ ម៉ែត្រការ៉េ ដែលមាននៅក្នុងប័ណ្ណលក់ ផ្ទះល្វែងទីផ្សារដើមគរលេខៈ ០៣ គ រ ជ .លអប ចុះថ្ងៃទី ០១ ខែមីនា ឆ្នាំ ១៩៩៣ ចេញដោយប្រធានគណៈ កម្មការរៀបចំផ្សា ដែលស្ថិតនៅភូមិអូរអំបិល សង្កាត់អូរអំបិល ក្រុងសិរីសោភ័ណ ខេត្តបន្ទាយមានជ័យ ជាដីកម្មសិទ្ធិរបស់ខ្លួន ដែលបានមកពីការទិញ ពីឈ្មោះ [redacted] អេងណៃ និង ប្តីឈ្មោះ [redacted] ហួរ ។

២- ចុងចម្លើយឈ្មោះ [redacted] សុឃីម បានអះអាងថា : ផ្ទះល្វែងទំហំ ៦៨ ម៉ែត្រការ៉េ ដែលស្ថិតនៅ ភូមិអូរអំបិល សង្កាត់អូរអំបិល ក្រុងសិរីសោភ័ណ ខេត្តបន្ទាយមានជ័យ ជាដីកម្មសិទ្ធិរបស់ខ្លួន ដែលខ្លួន និងប្តីបានមកពីការទិញ ។

- តើប្រាក់ថ្លៃទិញដី.ផ្ទះនិងប្រាក់ធ្វើផ្ទះ ជាប្រាក់របស់ឈ្មោះ [redacted] ថាច ឬជាប្រាក់របស់ឈ្មោះ [redacted] សុឃីម ឬជាប្រាក់របស់អតិត សពឈ្មោះ [redacted] គឹមហាង ?

## ការសំអាងហេតុ

ក្រោយពីបាន ស្តាប់សេចក្តី ថ្លែងការ របស់គូភាគី និងបានបញ្ចប់និតិវិធី ទាញហេតុផលដោយ ផ្ទាល់មាត់រួចមក តុលាការយល់ឃើញថា :-

១-ពាក្យបណ្តឹងចុះថ្ងៃទី១៥ ខែតុលា ឆ្នាំ២០១០ របស់ដើមចោទឈ្មោះ [redacted] ថាច ធ្វើឡើងក្នុងកំណត់ច្បាប់ តុលាការអាចលើករឿងនេះ យកមកពិនិត្យសម្រេចតាមបញ្ញត្តិច្បាប់ ។

២-ប័ណ្ណលក់ផ្ទះល្វែងទីផ្សារដើមគរលេខ : ០៣ គរជ/ល អ បចុះថ្ងៃទី០១ ខែមីនា ឆ្នាំ១៩៩៣ ដែលបានចុះហត្ថលេខា ដោយលោក [redacted] ពេជ្រ ជាប្រធានគណៈកម្មការរៀបចំផ្សារ គឺជាភស្តុតាងសំរាប់បញ្ជាក់ថា ដីទំនាស់ គឺ ជាទ្រព្យសម្បត្តិរបស់រដ្ឋ និង ជាភស្តុតាងសំរាប់បញ្ជាក់អំពី កិរិយាកាន់កាប់ដី ដំបូងបង្អស់ ក្នុងទីតាំងដីទំនាស់នេះ ដែលមានឈ្មោះ [redacted] អេងណៃ នឹងប្តីឈ្មោះ [redacted] ហួរ ជាម្ចាស់ដើម ដែលមានសិទ្ធិកាន់កាប់ ដើម្បីធ្វើអាជីវកម្មប្រចាំគ្រួសារ លើដីរបស់រដ្ឋទំហំ៦៨ ម៉ែត្រការ៉េ មានទីតាំងស្ថិតនៅភូមិអូរអំបិល សង្កាត់អូរអំបិល ក្រុងសិរីសោភ័ណ ខេត្តបន្ទាយមានជ័យ ។

៣- តាមលិខិតប្រគល់ទទួលប្រាក់ចំនួន ២៧០ ០០០ B ( ពីររយ ចិតសិប ពាន់បាត ) ចុះថ្ងៃទី ២១ ខែកញ្ញា ឆ្នាំ២០០១ រវាងឈ្មោះ [redacted] ថាច ជាអ្នកទិញ នឹងឈ្មោះ [redacted] អេងណៃ នឹងប្តីឈ្មោះ [redacted] ហួរ ជាអ្នកលក់ បានបញ្ជាក់ថា : ដីទំហំ៦៨ ម៉ែត្រការ៉េ ដែលមាននៅក្នុងប័ណ្ណលក់ ផ្ទះល្វែងទីផ្សារដើមគរលេខៈ០៣ គរជ.លអប ចុះថ្ងៃទី០១ ខែមីនា ឆ្នាំ ១៩៩៣បានចុះហត្ថលេខាដោយលោក [redacted] ពេជ្រ ជាប្រធានគណៈកម្មការរៀបចំផ្សារ ដែលស្ថិតនៅភូមិអូរអំបិល សង្កាត់អូរអំបិល ក្រុងសិរីសោភ័ណ ខេត្តបន្ទាយមានជ័យ គឺអាចបញ្ជាក់បានថា ឈ្មោះ [redacted] ថាច គឺជាអ្នកដែលមានសិទ្ធិកាន់កាប់អាស្រ័យផល បន្តពីឈ្មោះ [redacted] អេងណៃ នឹងប្តីឈ្មោះ [redacted] ហួរ ។/



Scanned with CamScanner

៥ ១
២

៤- តាមលិខិតប្រគល់ទទួលប្រាក់ ថ្លៃឈ្នួលជាង ចំនួន ៩៥ ០០០ B ( កៅសិបប្រាំ ពាន់បាត ) ចុះថ្ងៃទី ១០ ខែមិថុនា ឆ្នាំ២០០២ រវាងឈ្មោះ [redacted] ថាច នឹងឈ្មោះ [redacted] អាន នឹងលិខិតបញ្ជាក់ចុះថ្ងៃទី២៥ ខែវិច្ឆិកា ឆ្នាំ២០១០ របស់លោក [redacted] ពេជ្រ ចៅសង្កាត់អូរអំបិល បានបញ្ជាក់ថា : ប្រាក់ដែលបានចំណាយ លើការសាងសង់ ផ្ទះល្វែងសង់លើដីទំហំ៦៨ ម៉ែត្រការ៉េ ដែលមាននៅ ក្នុងប័ណ្ណ លក់ ផ្ទះល្វែងទីផ្សារដើមគរលេខ:០៣ គរជ.លអប ចុះថ្ងៃទី០១ ខែមីនា ឆ្នាំ១៩៩៣ ជាថវិការផ្ទាល់ខ្លួន របស់ដើមចោទឈ្មោះ [redacted] ថាច ។

៥-តាមចម្លើយសាក្សីដើមចោទឈ្មោះ [redacted] ម្សៀង ឈ្មោះ [redacted] ឈុនលី នឹងឈ្មោះ [redacted] ហៃ បានបញ្ជាក់ថា: ឈ្មោះ [redacted] ថាច បានទិញដីពីឈ្មោះ [redacted] អេងណៃ នឹងប្តីឈ្មោះ [redacted] ហួរ។ ចំពោះការអះអាងនេះ តុលាការនិងពិនិត្យពិចារណាតាមផ្លូវច្បាប់ ។

៦-ផ្អែកតាមការសំអាងហេតុចំណុចទី២ ទី៣ ទី៤ និងទី៥ អាចបញ្ជាក់ថាការអះអាង របស់ដើមចោទ ឈ្មោះ [redacted] ថាច មានភស្តុតាងដែលតុលាការអាចទទួលស្គាល់ថា ដី នឹងផ្ទះទំហំ៦៨ ម៉ែត្រការ៉េ មានទីតាំងស្ថិតនៅភូមិអូរអំបិល សង្កាត់អូរអំបិល ក្រុងសិរីសោភ័ណ ខេត្តបន្ទាយមានជ័យ គឺជារបស់ឈ្មោះ [redacted] ថាច ដែលជាអ្នកមានសិទ្ធិកាន់កាប់បន្តពីឈ្មោះ [redacted] អេងណៃ នឹងប្តីឈ្មោះ [redacted] ហួរ ។។

៧-តាមសេចក្តីថ្លែងការណ៍ និងតាមលិខិតផ្តល់ឯកសារ នៃមធ្យោបាយតទល់ នឹងការពារខ្លួន ចុះថ្ងៃទី១៩ ខែវិច្ឆិកា ឆ្នាំ២០១០ របស់ចុងចម្លើយឈ្មោះ [redacted] សុឃីម បានបញ្ជាក់ថា : ចុងចម្លើយឈ្មោះ [redacted] សុឃីម គ្មានឯកសារ ឬលិខិតលក់ទិញដី ដែលអាចឱ្យ តុលាការជឿបានថា ចុងចម្លើយគឺជាកម្មសិទ្ធិករ លើផ្ទះល្វែងទំហំ៦៨ ម៉ែត្រការ៉េ ដែលមាននៅក្នុងប័ណ្ណលក់ ផ្ទះល្វែងទីផ្សារដើមគរលេខ: ០៣ គ រ ជ .លអប ចុះថ្ងៃទី០១ ខែមីនា ឆ្នាំ១៩៩៣ ចេញដោយប្រធានគណៈកម្មការរៀបចំផ្សា នោះឡើយ ។

៨- ដើមចោទឈ្មោះ [redacted] ថាច ប្តឹងទាមទារជំងឺចិត្ត និងការខាតបង់ពេលវេលាក្នុងរឿងក្តី គិតជាប្រាក់ចំនួន ៥ ០០០ ០០០ រៀល ( ប្រាំលាន រៀល ) តុលាការគប្បីពិនិត្យសំរេច តាមសភាពជាក់ស្តែង ។

៩- ការចំណាយ និងសោហ៊ុយផ្សេងៗ ក្នុងដំណើរការបណ្តឹង ជាបន្ទុករបស់ភាគីចាញ់ក្តី ។

## <u>សេចក្តីសម្រេចបញ្ច ប់</u>

១-បញ្ជាក់ទទួលស្គាល់សិទ្ធិកាន់កាប់អាស្រ័យផលអចលនវត្ថុ នៃដីនឹងផ្ទះល្វែងទំហំ៦៨ ម៉ែត្រការ៉េដែលមាននៅក្នុងប័ណ្ណលក់ផ្ទះល្វែងទីផ្សារដើមគរលេខ:០៣ គ រ ជ .លអប ចុះថ្ងៃទី ០១ ខែមីនា ឆ្នាំ ១៩៩៣ ចេញដោយប្រធានគណៈកម្មការរៀប ចំផ្សា ដែលស្ថិតនៅភូមិអូរអំបិល សង្កាត់អូរអំបិល ក្រុងសិរីសោភ័ណ ខេត្តបន្ទាយមានជ័យ ជារបស់ឈ្មោះ ហុង ថាចប៉ុន្តែ ក្នុងករណីយរដ្ឋត្រូវការ ត្រូវប្រគល់ជូនរដ្ឋវិញ ។

២-បង្គាប់ឱ្យ ចុងចម្លើយឈ្មោះ [redacted] សុឃីម ប្រគល់អចលនវត្ថុ នៃដីនឹងផ្ទះល្វែងទំហំ៦៨ ម៉ែត្រការ៉េ ដែលមាននៅក្នុងប័ណ្ណលក់ផ្ទះល្វែងទីផ្សាដើមគរលេខ: ០៣ គរជ/ល អ បចុះថ្ងៃទី០១ ខែមីនា ឆ្នាំ១៩៩៣ ចេញដោយប្រធានគណៈកម្មការរៀបចំផ្សារ ដែលស្ថិតនៅភូមិអូរអំបិល សង្កាត់អូរអំបិល ក្រុងសិរីសោភ័ណ ខេត្តបន្ទាយមានជ័យ ឱ្យទៅឈ្មោះ [redacted] ថាច ដើម្បីគ្រប់គ្រងកាន់កាប់អាស្រ័យផលតាមច្បាប់ ។



Scanned with CamScanner

៣-បង្គាប់ឱ្យ ចុងចម្លើយឈ្មោះ [redacted] សុឃីម ចុះចេញពី ដីនិងផ្ទះល្វែងទំហំ៦៨ ម៉ែត្រការ៉េដែលមាន នៅក្នុងប័ណ្ណលក់ផ្ទះល្វែងទីផ្សាដើមគរលេខ០៣ គរជ/ល អ បចុះថ្ងៃទី០១ ខែមីនា ឆ្នាំ១៩៩៣ ចេញដោយប្រធានគណៈកម្មការរៀបចំផ្សារ ដែលស្ថិតនៅភូមិអូរអំបិល សង្កាត់អូរអំបិល ក្រុងសិរីសោភ័ណ ខេត្តបន្ទាយមានជ័យ ។

៤-បង្គាប់ឱ្យចុងចម្លើយ ឈ្មោះ [redacted] សុឃីម សងប្រាក់ជំងឺចិត្ត និងការបង់ខាតពេលវេលាចំនួន ៥ ០០០ ០០០ រៀល ( បីលានរៀល ) ឱ្យទៅដើមចោទឈ្មោះ [redacted] ថាច ។

៥- បង្គាប់ឱ្យចុងចម្លើយឈ្មោះ [redacted] សុឃីម ទទួលបន្ទុកលើប្រាក់ពន្ធលើពាក្យបណ្ដឹង និង ប្រាក់ប្រដាប់ក្ដីផ្សេងៗ ទាំងអស់ ។

ធ្វើនៅ បន្ទាយមានជ័យ ថ្ងៃទី២២ ខែកុម្ភៈ ឆ្នាំ២០១១

ចៅក្រមសាលាដំបូងខេត្ត

[redacted]

**យល់ឃើញថា :**

-នៅចំណុចទី៤ នៃសេចក្ដីវិនិច្ឆ័យ មានការសរសេរជាអក្សរថា :( បីលានរៀល ) នោះ ត្រូវកែតម្រូវអក្សរទៅពាក្យថា ( ប្រាំលានរៀល ) វិញ ។

**ហេតុដូច្នេះសម្រេចកែតម្រូវ :**

៤-បង្គាប់ឱ្យចុងចម្លើយ ឈ្មោះ [redacted] សុឃីម សងប្រាក់ជំងឺចិត្ត និងការបង់ខាតពេលវេលាចំនួន ៥ ០០០ ០០០ រៀល ( ប្រាំលានរៀល ) ឱ្យទៅដើមចោទឈ្មោះ [redacted] ថាច ។

ក្រឡាបញ្ជី

[redacted]

ចៅក្រមសាលាដំបូងខេត្ត

[redacted]



Scanned with CamScanner